ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល
លេខ: ៤៤៤
ថ្ងៃ: ព្រហ.ទី.៣០ ខែ.ធ្នូ ឆ្នាំ២០២០
ម៉ោង: ១០:០០ នាទី

# ព្រះរាជក្រម

នស/រកម/១២២០/០៤០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីមូលបត្ររដ្ឋ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

# ច្បាប់
# ស្តីពី
# មូលបត្ររដ្ឋ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងផ្តល់នូវក្របខ័ណ្ឌរួមសម្រាប់គ្រប់គ្រងការបោះផ្សាយ ការជួញដូរ និងការគ្រប់គ្រងមូលបត្ររដ្ឋ ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ព្រមទាំងធានាបាននូវចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ សំដៅរួមចំណែក៖

១-ពង្រឹងការគ្រប់គ្រងតម្រូវការសាច់ប្រាក់របស់រាជរដ្ឋាភិបាល។

២-ឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទាន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។

៣-អភិវឌ្ឍទីផ្សារមូលបត្រ និងទីផ្សារហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤-គាំទ្រគម្រោងអាទិភាព និងចាំបាច់ផ្សេងទៀត។

**មាត្រា២ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការបោះផ្សាយ ការជួញដូរ និងការគ្រប់គ្រងមូលបត្ររដ្ឋនៅក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងច្បាប់នេះ មានដូចខាងក្រោម៖

**១-គណនី** សំដៅដល់គណនីទូទៅនិងគណនីពិសេសរបស់អគ្គនាយកដ្ឋានរតនាគារជាតិដូចមានចែងនៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលមានជាធរមាន និងគណនីពិសេសផ្សេងទៀតដែលបានបង្កើតដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**២-គូប៉ុង** សំដៅដល់ការប្រាក់ដែលត្រូវទូទាត់តាមលក្ខខណ្ឌនៃមូលបត្ររដ្ឋដែលបោះផ្សាយដោយអនុលោមតាមច្បាប់នេះ។

**៣-បរិវិសកម្ម** សំដៅដល់ការដាក់សំណើសុំទិញមូលបត្ររដ្ឋដែលបោះផ្សាយដោយអនុលោមតាមច្បាប់នេះ។

**៤-មូលបត្ររដ្ឋ** សំដៅដល់បណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុលដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាលនៅក្រោមច្បាប់នេះ រួមមាន៖

ក-បណ្ណរតនាគារដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ។

ខ-សញ្ញាបណ្ណរតនាគារដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ។

គ-មូលបត្ររដ្ឋផ្សេងទៀត។

មូលបត្ររដ្ឋទាំងអស់ខាងលើនេះ មិនរួមបញ្ចូលនូវមូលបត្រដែលបោះផ្សាយដោយសហគ្រាសសាធារណៈ [illegible]ការរបស់រាជរដ្ឋាភិបាលដែលមិនស្ថិតក្រោមវិសាលភាពនៃច្បាប់នេះទេ។

**៥-រដ្ឋមន្ត្រី** សំដៅដល់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**៦-រាជរដ្ឋាភិបាល** សំដៅដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

**៧-វិញ្ញាបនបត្រមូលបត្ររដ្ឋ** សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរដោយមានការធានានូវការបំពេញកាតព្វកិច្ចទូទាត់ពេញលេញពីរាជរដ្ឋាភិបាល ដោយមានចែងអំពីរយៈពេល លក្ខខណ្ឌ និងកាតព្វកិច្ចផ្សេងៗទៀតរបស់មូលបត្រនោះ។

**៨-ឥណប្រតិទាន** សំដៅដល់កាលបរិច្ឆេទដែលមូលបត្រត្រូវដល់កាលកំណត់សង។

## ជំពូកទី២

## ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋ

**មាត្រា៤ .-**

ការបោះផ្សាយមូលបត្ររដ្ឋ ត្រូវអនុវត្តដូចខាងក្រោម៖

ក- ស្ថិតក្រោមការកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីមួយគត់ដែលអាចបោះផ្សាយមូលបត្ររដ្ឋដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឬច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ រដ្ឋមន្ត្រីអាចផ្តល់ប្រាក់វិញ ទិញមកវិញ និងទូទាត់សង នូវរាល់មូលបត្ររដ្ឋដែលដល់ឬមិនទាន់ដល់ឥណប្រតិទាន។ ការបោះផ្សាយមូលបត្ររដ្ឋត្រូវកំណត់ឱ្យបានច្បាស់លាស់នូវមុខសញ្ញាចំណាយនៃតម្រូវការហិរញ្ញប្បទានរបស់រដ្ឋ។

ខ- រាល់ប្រតិបត្តិការពាក់ព័ន្ធនឹងការបោះផ្សាយនិងការគ្រប់គ្រងមូលបត្ររដ្ឋ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី។

គ- ដូចមានចែងក្នុងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា និងច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន រាល់ការងារបច្ចេកទេសនិងប្រតិបត្តិការទាក់ទងនឹងមូលបត្ររដ្ឋអាចអនុវត្តដោយធនាគារជាតិនៃកម្ពុជានិង/ឬទីផ្សារមូលបត្រប្រតិស្រុត តាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី លើកលែងតែមានចែងក្នុងច្បាប់ផ្សេងទៀត។ ធនាគារជាតិនៃកម្ពុជាត្រូវបង្កើតនីតិវិធីដើម្បីបែងចែកឱ្យដាច់ដោយឡែកពីគ្នានូវមុខងារប្រតិបត្តិការទាក់ទងនឹងមូលបត្ររដ្ឋ និងមុខងារគោលនយោបាយរូបិយវត្ថុ។

មូលបត្ររដ្ឋអាចត្រូវបានបោះផ្សាយជារូបិយវត្ថុជាតិឬជារូបិយបណ្ណបរទេស។

មូលបត្ររដ្ឋអាចត្រូវបានបោះផ្សាយក្នុងប្រទេសឬនៅក្រៅប្រទេស តាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី។

មូលបត្ររដ្ឋដែលត្រូវបានបោះផ្សាយលក់ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

ចំនួនទឹកប្រាក់សរុបនៃការបោះផ្សាយមូលបត្ររដ្ឋ ត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

នាយករដ្ឋមន្ត្រីត្រូវធ្វើសំណើទៅរដ្ឋសភា ដើម្បីសុំការអនុម័តលើការបោះផ្សាយមូលបត្ររដ្ឋបន្ថែមទៅលើចំនួនទឹកប្រាក់សរុបដែលរដ្ឋសភាបានអនុម័តរួចហើយ ដោយត្រូវបញ្ជាក់ពីគោលបំណងនៃការបោះផ្សាយមូលបត្ររដ្ឋបន្ថែមនេះ។

**មាត្រា៦ .-**

មូលបត្ររដ្ឋអាចត្រូវបានបោះផ្សាយក្នុងទម្រង់វិញ្ញាបនបត្រឬទម្រង់អេឡិចត្រូនិច ដែលអាចបង្ហាញបាននិងបោះពុម្ពជាទម្រង់ដែលអាចអានបាន។

**មាត្រា៧ .-**

អ្នកចូលរួមដោយផ្ទាល់ក្នុងទីផ្សារដំបូងអាចជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ឬក្រុមហ៊ុនមូលបត្រដែលបានទទួលអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា ឬស្ថាប័នផ្សេងទៀត តាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី។ អ្នកចូលរួមដោយផ្ទាល់ក្នុងទីផ្សារដំបូងអាចដេញថ្លៃនិង/ ឬធ្វើបរិវិសកម្មទៅលើមូលបត្ររដ្ឋ ក្នុងនាមខ្លួនឯងនិង/ ឬក្នុងនាមជាភ្នាក់ងាររបស់បុគ្គលផ្សេងទៀត។

**មាត្រា៨ .-**

មូលបត្ររដ្ឋអាចត្រូវបានដាក់លក់ជាសាធារណៈនៅទីផ្សារដំបូង ដោយការដេញថ្លៃឬវិធីសាស្ត្រផ្សេងតាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី។

**មាត្រា៩ .-**

ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ព្រមទាំងធានាប្រសិទ្ធភាពនិងតម្លាភាពនៃការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋ រដ្ឋមន្ត្រីត្រូវកំណត់ដោយប្រកាសនូវៈ

ក- វិធីសាស្ត្រនិងយន្តការនៃការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋ។

ខ- ទម្រង់និងដំណើរការពាក់ព័ន្ធនឹងការគ្រប់គ្រងមូលបត្ររដ្ឋដែលត្រូវបោះផ្សាយ។

គ- អ្នកចូលរួមដោយផ្ទាល់និងអ្នកដែលមានសិទ្ធិក្នុងការចូលរួមក្នុងទីផ្សារដំបូង។

ឃ- ការកត់ត្រាអ្នកធ្វើបរិវិសកម្ម។

ង- ការរក្សាទុកមូលបត្ររដ្ឋនៅប្រតិបត្តិកររក្សាទុកណាមួយ និងការចុះបញ្ជីជួញដូរមូលបត្ររដ្ឋនៅទីផ្សារមូលបត្រប្រតិស្រុត។

ច- ការទូទាត់ប្រាក់ដើមនិងអត្រាគូប៉ុងនៃមូលបត្ររដ្ឋ និងធាតុសំខាន់ផ្សេងៗទៀត។

**មាត្រា១០ .-**

មានតែគណនីចរន្តនៃរតនាគារជាតិនៅធនាគារជាតិនៃកម្ពុជា នឹងត្រូវបានប្រើប្រាស់ដោយរដ្ឋមន្ត្រីក្នុងគោលបំណងគ្រប់គ្រងមូលបត្ររដ្ឋ។

ចំណូលបានមកពីការបោះផ្សាយមូលបត្ររដ្ឋត្រូវបង្វែរចូលគណនីចរន្តសម្រាប់ចំណូលពីការបោះផ្សាយមូលបត្ររដ្ឋ ដែលជាអនុគណនីផ្នែកចំណូលនៃគណនីទោលរតនាគារជាតិ។ ចំណូលពីការបោះផ្សាយមូលបត្ររដ្ឋត្រូវតែកត់ត្រាក្នុងមាតិកាចំណូលថវិការបស់រដ្ឋ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ចំណាយលើការទូទាត់អត្រាគូប៉ុងនិងការទូទាត់ប្រាក់ដើម ឬការទិញត្រឡប់មកវិញនៃមូលបត្ររដ្ឋ ត្រូវធ្វើឡើងតាមរយៈគណនីទោលរតនាគារជាតិ និងត្រូវកំណត់ក្នុងខ្ទង់មាតិកាចំណាយថវិការបស់រដ្ឋ។

**មាត្រា១១ .-**

សិទ្ធិប្តឹងទាមទារសំណងនូវចំនួនទឹកប្រាក់នៃមូលបត្ររដ្ឋត្រូវអនុវត្តក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ ចំពោះប្រាក់ដើមនិងគូប៉ុងគិតចាប់ពីឥណប្រតិទាន។ អាជ្ញាយុកាលនេះត្រូវបង្អង់ឬផ្អាកដោយអនុលោមតាមក្រមរដ្ឋប្បវេណីនិងបទប្បញ្ញត្តិជាធរមាន។

ទ្រព្យសកម្មសាធារណៈនិងប្រាក់ចំណូលរបស់រដ្ឋ ត្រូវបានការពារពីការរឹបអូសនិងការហាមឃាត់ផ្សេងៗ។

**មាត្រា១២ .-**

រាល់ប្រតិបត្តិការជួញដូរមូលបត្ររដ្ឋត្រូវស្ថិតក្រោមនីតិរបបនៃរបបសារពើពន្ធជាធរមាន និងអាចទទួលបានការលើកទឹកចិត្តនិងការអនុគ្រោះនានា ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៣

## ទីផ្សារបន្ទាប់នៃមូលបត្ររដ្ឋ

**មាត្រា១៣ .-**

ការជួញដូរ ការផ្ទេរ ឬការដាក់ប្រាតិភោគនៃមូលបត្ររដ្ឋ ដោយធនាគារជាតិនៃកម្ពុជា ឬដោយអ្នកចូលរួមនៅក្នុងទីផ្សារអន្តរធនាគារ ឬទីផ្សារមូលបត្រប្រតិស្រុត ឬដោយអ្នកដែលមានសិទ្ធិចូលរួមផ្សេងទៀត ព្រមទាំងយន្តការពាក់ព័ន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី។

អ្នកចូលរួមដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ អាចជួញដូរ ផ្ទេរ ឬដាក់ប្រាតិភោគមូលបត្ររដ្ឋសម្រាប់ខ្លួនឯងនិង/ឬជាភ្នាក់ងាររបស់បុគ្គលផ្សេងទៀត។

សិទ្ធិនិងការទទួលខុសត្រូវរបស់អ្នកចូលរួមដូចមានចែងនៅក្នុងកថាខណ្ឌទី១នៃមាត្រានេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី។

## ជំពូកទី៤

## ទោសប្បញ្ញត្តិ

**មាត្រា១៤ .-**

បុគ្គលដែលក្លែងមូលបត្ររដ្ឋតាមរូបភាពណាក៏ដោយ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនប្រព្រឹត្តនិងត្រូវផ្តន្ទាទោសស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៥ .-**

បុគ្គលិក ឬមន្ត្រី ដែលពាក់ព័ន្ធក្នុងការអនុវត្តដេញថ្លៃ ឬពាក់ព័ន្ធក្នុងកាតព្វកិច្ចផ្សេងទៀត ហើយមិនបានបំពេញត្រឹមត្រូវតាមការកំណត់របស់ច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនប្រព្រឹត្តនិងត្រូវផ្តន្ទាទោសស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៦ .-**

ច្បាប់ស្តីពីមូលបត្ររដ្ឋដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ សុក្រ ៦កើត ខែ បឋមាសាឍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០២០

នស/រកម/០៦២០/០១៤

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**